# អរិយធម៌ ហ្ស៊ីមបាវ៉េ ( Civilization of Zimbabwe )

ក្រេច ហ្ស៊ីមបាវ៉េ (Great Zimbabwe) គឺជាឈ្មោះនៃទីក្រុងបុរាណដ៏សំខាន់មួយដែលបង្ហាញអំពីអរិយធម៌នៃអាណាចក្រ ហ្ស៊ីមបាវ៉េ ហើយសព្វថ្ងៃស្ថិតនៅខាងជើងនៃប្រទេសហ្ស៊ីមបាវ៉េ(Zimbabwe)។ នៅក្នុងទឹកដីនៃតំបន់អរិយធម៌នេះ សំបូរដោយជនជាតិ បុនទូ (Buntu) ដែលជាជនជាតិបុរាណរស់នៅក្នុងទឹកដីនៃប្រទេសអាហ្វ្រិចខាងត្បូងមួយនេះតាំងពីដើម។[១] Zimbabwe ក្នុងភាសា Buntu មានន័យថា ផ្ទះថ្ម ( stone house)។[២]

អរិយធម៌ ឬអាណាចក្រ ហ្ស៊ីមបាវ៉េ គឺជាផ្នែកមួយដ៏សំខាន់នៃបណ្ដាញផ្លូវពាណិជ្ជកម្មនៅក្នុងតំបន់អាហ្វ្រិចខាងជើង (រូបលេខ១)។ តាមរយៈការសិក្សាផ្នែកបុរាណវិទ្យានៅក្នុងតំបន់នេះ អ្នកបុរាណវិទូបានរកឃើញនូវកុលាលភាជន៍ដែលមានប្រភពមកពីចិន ពែក្ស និងជាពិសេសកាក់ប្រាក់ដែលមកពីតំបន់អារ៉ាប់ជាដើម។ ការរកឃើញនៃវត្ថុតាងទាំងនោះបានបង្ហាញអំពីវិសាលភាពនៃការជួញដូររវាងអរិយធម៌នេះ និងអរិយធម៌ដទៃទៀត។

ទីក្រុង ក្រេច ហ្ស៊ីមបាវ៉េ ( (Great Zimbabwe) គឺមានចម្ងាយប្រមាណជាង ៣០គីឡូពីទីក្រុង Masvingo និងស្ថិតនៅខាងជើងនៃប្រទេសហ្ស៊ីមបាវ៉េ។ ទីក្រុងបុរាណនេះ គឺជារាជធានីដ៏សំខាន់នៃអាណាចក្រ Zimbabwe និងត្រូវបានបង្កើតឡើងប្រហែលស. វ.ទី១២ នៃគ.ស. និងត្រូវបានបោះបង់ចោលនៅស.វ.ទី១៥ ពោលគឺស្ថិតនៅចន្លោះឆ្នាំ១១០០ដល់ឆ្នាំ១៤៥០នៃគ.ស.។ ទីក្រុងនេះមានផ្ទៃដីជាង៨០០ហិចតា ដោយបែងចែកជាបីតំបន់ផ្សេងៗ គឺតំបន់មានប្រាសាទនៅលើភ្នំ (Hill Ruins), តំបន់មានជញ្ជាំងខ្ពស់ (Great Enclosure) និងតំបន់ប្រាសាទនៅតាមជ្រលងភ្នំ ទន្លេ (Valley Ruins)[៣] ( រូបលេខ២-៥ )។

តំបន់មានប្រាសាទលើភ្នំ គឺជាបណ្ដុំនៃសំណង់ប្រាសាទដែលកសាងចាប់ពីកំពូលភ្នំដេញរហូតដល់ចង្កេះភ្នំ។ ចំពោះទីតាំងនេះ កសាងសម្រាប់កន្លែងប្រារព្ធពិធីសាសនា ហើយ

---

[១] https://www.nationalgeographic.org/

[២] ibid

[៣] https://whc.unesco.org/en/list/364

អត្ថបទដោយ៖ អេង តុលា

តំបន់នេះ គឺចាស់ជាងតំបន់ពីរផ្សេងទៀត ដែលប្រហែលជាកសាងនៅស.វ.ទី១០ នៃគ.ស។ តំបន់នេះចាត់ទុកជាវាំង និងជាកន្លែងសំខាន់នៃក្រុង ហ្ស៊ីមបាវ៉េទាំងមូល។[៤]

តំបន់ទី២ គឺជាតំបន់មានជញ្ជាំងខ្ពស់ ដែលស្ថិតនៅខាងត្បូង នៃតំបន់ទី១ ដោយនៅទីនេះកសាងជញ្ជាំងអំពីថ្ម ដែលមានកំពស់៩.៧ ម៉ែត្រ និងកសាងនៅស.វ.ទី ១៤នៃគ.ស។ បច្ចេកទេសភ្ជាប់ថ្មនៅទីនេះ គឺប្រើប្រាស់ជាមួយនឹង Mortar។[៥]

រីឯតំបន់ទី៣វិញ គឺជាតំបន់ដែលមានផ្ទះប្រជាជនរស់នៅ ស្ថិតនៅក្បែរនឹងតំបន់ទី២ ដោយផ្ទះទាំងនោះធ្វើពីភក់លាយជាមួយដីឥដ្ឋ (Daga)។ នៅក្នុងតំបន់នេះអ្នកស្រាវជ្រាវបានធ្វើការស្ទង់មានប្រជាជនរស់នៅប្រមាណ១០,០០០ ទៅ ២០,០០០នាក់។[៦]

តាមរយៈជនជាតិព័រទុយកាលដែលបានមកដល់តំបន់នេះ គឺនៅអំឡុងពាក់កណ្ដាល ស.វ.ទី១៥ បានបង្ហាញថា ទឹកដីនៃអាណាចក្រហ្ស៊ីមបាវ៉េត្រូវបានបែងចែកជាពីរផ្នែកដែលគ្រប់គ្រងដោយអាណាចក្រ Torwa និងមួយផ្នែកទៀតដោយអាណាចក្រ Mwene-Mutapa។[៧]

តាមរយៈការស្រាវជ្រាវជាច្រើននៅក្នុងតំបន់នេះបានបង្ហាញទីតាំងនេះ គឺមានមនុស្សរស់នៅតាំងពីសម័យបុរេប្រវត្តិ ( ក្រុមមនុស្សបុនទូ ) និងរហូតដល់សម័យកាលអាណាចក្រ ហ្ស៊ីមបាវ៉េ ដែលជាអរិយធម៌ដ៏រីកចម្រើន និងមានបច្ចេកទេសខ្ពស់ក្នុងការរៀបចំក្រុង យ៉ាងល្អបែបនេះ ។ ប៉ុន្តែអាណាចក្រនេះក៏ត្រូវបានដួលរលំវិញដែរ នៅអំឡុង ស.វ.ទី ១៥ ដោយកត្តាជាច្រើន ។ ប្រហែលមកក្រុមមនុស្សផ្សេងចូលមករស់នៅក្នុងតំបន់នេះកាន់តែច្រើន និងមកពីកត្តាធម្មជាតិ ជាដើម។

[៤] https://www.metmuseum.org/

[៥] https://www.google.com/search?q=mortar&oq=mortar&aqs=chrome..69i57j0i271l2.794j0j7&sourceid=chrome&ie=UTF-8

[៦] https://www.nationalgeographic.org/

[៧] https://whc.unesco.org/en/list/364

អត្ថបទដោយ៖ អេង តុលា




រូបលេខ១ ផែនទីទឹកដី នៃប្រទេសហ្ស៊ីមបាវ៉េ

ប្រភព៖ https://www.khanacademy.org/humanities/art-africa/southern-africa/zimbabwe/a/great-

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION






រូបលេខ២ & ៣ ៖ប្លង់និងពីលើអាកាស នៃក្រុង Great Zimbabwe

ប្រភព៖ https://www.khanacademy.org/





រូបលេខ៤ & ៥៖ តំបន់ទី ១ និងទី២

ប្រភព៖ [https://www.khanacademy.org/](https://www.khanacademy.org/)

អត្ថបទដោយ៖ អេង តុលា



រូបលេខ ៦៖ ផ្ទះ daga ធ្វើលើវិញនៅតំបន់ទី៣

ប្រភព៖ https://www.wikipedia.org/

## ឯកសារយោង


https://www.google.com/search?q=mortar&oq=mortar&aqs=chrome..69i57j0i271l2.794j0j7&sourceid=chrome&ie=UTF-8

https://www.nationalgeographic.org/

https://whc.unesco.org/en/list/364

https://www.metmuseum.org/


អត្ថបទដោយ៖ អេង តុលា